ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា

# សេចក្ដីប្រកាសព័ត៌មាន

ដោយមានការយកចិត្តទុកដាក់ដ៏ខ្ពង់ខ្ពស់បំផុតពី **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និង**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត** ចំពោះសុខទុក្ខ សុវត្ថិភាព សុខភាព និងសិទ្ធិរបស់ទាហានកម្ពុជាទាំង១៨នាក់ ដែលកំពុងត្រូវបានឃុំខ្លួននៅប្រទេសថៃ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា (គ.ស.ម.ក.) ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាលកម្ពុជា សូមជម្រាបជូនដំណឹងដល់សាធារណជនជ្រាបថា ក្រោយកិច្ចព្រមព្រៀងឈប់បាញ់ចូលជាធរមានរយៈពេលប្រមាណ៨ម៉ោង នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៥ ថៃបានចល័តទ័ពចូលមកចាប់ទាហានកម្ពុជាចំនួន២០នាក់ ក្នុងបន្ទាយកងទ័ពកម្ពុជា។ ដោយបានឃើញទាហានកម្ពុជាចំនួន២នាក់ ក្នុងចំណោម២០នាក់ ដែលត្រូវបានដោះលែង មានស្ថានភាពសុខភាពធ្ងន់ធ្ងរ នៅថ្ងៃទី១ ខែសីហា ឆ្នាំ២០២៥ គ.ស.ម.ក. បានដាក់ញត្តិបន្ទាន់ជូន ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស នៅទីក្រុងហ្សឺណែវ និងប្រធានប្ដូរវេននៃគណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្ស (អាយឆា-AICHR)។

ដើម្បីជំរុញការធ្វើទស្សនកិច្ច និងអធិការកិច្ចរបស់សហគមន៍ អង្គការអន្តរជាតិ និងយន្តការសិទ្ធិមនុស្សនានា នៅកន្លែងឃុំឃាំងទាហានកម្ពុជាទាំង១៨នាក់ គ.ស.ម.ក. បានផ្ញើលិខិតអន្តរាគមន៍បន្ថែមទៀតជូន៖

- តំណាងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ប្រចាំតំបន់អាស៊ីអាគ្នេយ៍
- ប្រធានស្ថាប័នសិទ្ធិមនុស្សជាតិឯករាជ្យរបស់ប្រទេសថៃ
- តំណាងប្រទេសថៃប្រចាំគណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្ស (អាយឆា)
- ប្រធានស្ថាប័នសិទ្ធិមនុស្សជាតិឯករាជ្យរបស់ប្រទេសម៉ាឡេស៊ី។

**ក្នុងលិខិតអន្តរាគមន៍ គ.ស.ម.ក. បានស្នើសុំឱ្យ អ្នកតំណាង និងប្រធានស្ថាប័នខាងលើ៖**

- ធ្វើទស្សនកិច្ចបែបមនុស្សធម៌នៅកន្លែងឃុំខ្លួនទាហានកម្ពុជាទាំង១៨នាក់
- ផ្ទៀងផ្ទាត់សុខុមាលភាពផ្លូវកាយ និងផ្លូវចិត្តរបស់ទាហាន និងលក្ខខណ្ឌដែលពួកគេត្រូវបានឃុំខ្លួន
- ជួយ និងសម្របសម្រួលទំនាក់ទំនងរវាងទាហានទាំង១៨នាក់ និងគ្រួសាររបស់ពួកគេ និងអ្នកពាក់ព័ន្ធផ្សេងទៀត

អគារលេខ៣ ផ្លូវ VI.13 ភូមិទួលសំពៅ សង្កាត់ទួលសង្កែ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
Building #3, Street VI.13, Toul Kok Village, Sangkat Toul Sangke, Khan Russey Keo, Phnom Penh Tel: (855) 23 882 065

- **ជានាឱ្យមានការដោះលែងជាបន្ទាន់** និងការព្យាបាលស្របតាមច្បាប់ គោលការណ៍មនុស្សធម៌បទដ្ឋានអន្តរជាតិ និងគោលការណ៍អាស៊ាន។

ដោយកត់សម្គាល់ឃើញថា ប្រទេសថៃជាប្រទេសធ្លាប់យកចិត្តទុកដាក់លើវិស័យសិទ្ធិមនុស្ស និងមានធនធានបញ្ញវន្តផ្នែកសិទ្ធិមនុស្សជាច្រើនរូប គ.ស.ម.ក. មានសុទិដ្ឋិនិយមខ្ពស់ថា ទាហានកម្ពុជាទាំង ១៨នាក់ នឹងត្រូវបានដោះលែង និងបញ្ជូនមកប្រទេសកម្ពុជាវិញក្នុងពេលដ៏ឆាប់បំផុត។

គ.ស.ម.ក. នឹងខិតខំប្រឹងប្រែងបន្ថែមទៀត និងសូមអំពាវនាវដល់ឃោជាថៃ សូមដោះលែង និងបញ្ជូនទាហានកម្ពុជាទាំង១៨នាក់ មកប្រទេសកម្ពុជាវិញ ដើម្បីជានាទំនុកចិត្តរវាងរាជរដ្ឋាភិបាល និងរវាងប្រជាជននៃប្រទេសទាំងពីរ ព្រមទាំងប្រែក្លាយព្រំដែននៃប្រទេសទាំងពីរទៅជាព្រំដែននៃកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍ។

គ.ស.ម.ក. សង្ឃឹមថា ស្ថាប័នខាងលើនឹងធ្វើកិច្ចអន្តរាគមន៍សម្របសម្រួល និងចុះពិនិត្យតាមសំណើរបស់ គ.ស.ម.ក. ក្នុងពេលដ៏ឆាប់បំផុត។

ប្រទេសកម្ពុជាប្តេជ្ញាអនុវត្តតាមច្បាប់អន្តរជាតិ រួមទាំងធម្មនុញ្ញអង្គការសហប្រជាជាតិ ច្បាប់មនុស្សធម៌អន្តរជាតិ និងសន្ធិសញ្ញាសិទ្ធិមនុស្សដែលពាក់ព័ន្ធទាំងអស់ និងខិតខំលើកកម្ពស់សុខដុមរមនា យុត្តិធម៌ និងការរួមរស់ដោយសន្តិភាពក្នុងចំណោមប្រជាជាតិនានា។

ថ្ងៃចន្ទ ១០កើត ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី៤ ខែសីហា ឆ្នាំ២០២៥